# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីពុទ្ធភាសិតមួយបទពោលថា កម្មតែងចែកសត្វទាំងឡាយឲ្យថោកទាបនិងខ្ពង់ខ្ពស់ថ្លៃថ្លា

web site: hoksavann.org

ថ្ងៃទី២១ កុម្ភៈ ២០០៥

ពាក្យថា <កម្ម> តែចែកសត្វទាំងឡាយឲ្យថោកទាបនិងខ្ពង់ខ្ពស់ថ្លៃថ្លា ចេញពីពុទ្ធភាសិតថា កម្មំ សត្តេ វិភជ្ជតិ ហីនប្បណីតតាយ ។ <កម្ម> ក្នុងន័យព្រះពុទ្ធសាសនា ក៏សំដៅយកអំពើប្រកបដោយចេតនា គឺប៉ង ធ្វើដូចពុទ្ធភាសិតថា ចេតនាហំ ភិក្ខវេ កម្មំ វទាមិ ប្រែថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ចេតនាជាតួកម្ម ។ បើធ្វើតាមផ្លូវកាយ ហៅថាកាយកម្ម តាមផ្លូវវាចាហៅថាវចីកម្ម, តាមផ្លូវចិត្តហៅថាមនោកម្ម ។ ចេតនាជាតួចេតសិកធម៌ គឺជាសកម្មភាពរបស់ចិត្តដែលប្រព្រឹត្តនៅក្នុងអារម្មណ៍ ។ ពាក្យថា <ចេតនា> គឺជាអំពើប្រកបដោយចិត្តក្លែង ឬហៅថាសចិត្តក: ។ អំពើដែលពុំមានចិត្តនិងចេតសិកនៅជាមួយទេ ពុំឈ្មោះថាកម្មក្នុងពុទ្ធសាសនាឡើយ ។ កម្មដែលប្រែថាអំពើនោះមានពីរយ៉ាង គឺកុសលកម្ម អំពើល្អ និងអកុសលកម្មអំពើអាក្រក់ ។ ល្អអាក្រក់នោះចេញមកពីអំពើខ្លួនឯង បាលីថា កម្មស្សកោម្ហិ ប្រែថាសត្វទាំងឡាយមានកម្មជារបស់ខ្លួន ។ ដូច្នេះបញ្ជាក់ថា សេចក្តីសុខទុក្ខចំរើនវិនាស កើតចេញមកអំពីរបស់ខ្លួនដែលហៅថា<កម្ម>នេះឯង ។ ស្របបឹងពុទ្ធភាសិតមួយបទទៀតពោលថា កម្មុនា វត្តតី លោកោ ប្រែថា សត្វទាំងឡាយប្រព្រឹត្តទៅតាមអំពើរបស់ខ្លួន ចំណែកព្រះពុទ្ធព្រះអង្គគ្រាន់តែចង្អុលបង្ហាញផ្លូវប៉ុណ្ណោះ ។ ដូច្នេះពុទ្ធសាសនាបានបដិសេធនូវទ្រឹស្តីថា សេចក្តីសុខទុក្ខចំរើនវិនាស កើតចេញពីព្រះជាម្ចាស់អង្គណាមួយផ្តល់ឲ្យ ។ ដើម្បីបញ្ជាក់រឿងនេះទៀត មានពុទ្ធភាសិតមួយបទពោលថា សេចក្តីបរិសុទ្ធនិងមិនបរិសុទ្ធដោយខ្លួនឯង អ្នកដទៃមិនអាចញ៉ាំងអ្នកដទៃឲ្យបរិសុទ្ធ និងឲ្យសៅហ្មងបានឡើយ (សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ) កម្មផលនេះហើយដែលធ្វើឲ្យមនុស្សសត្វមានលក្ខណ:ផ្សេងគ្នាទាំងរូបរាងកាយ ទាំងចិត្តគំនិត និងការរស់នៅ ។ ព្រះពុទ្ធសំដែងថា មនុស្សថោកទាបនិងខ្ពង់ខ្ពស់ថ្លៃថ្លា ពុំមែនស្ថិតនៅលើជាតិត្រកូល ទ្រព្យសម្បត្តិ យសស័ក្តិឡើយ តែស្ថិតនៅលើអំពើដែលគេធ្វើ ។ បានសេចក្តីថា បើអ្នកមានជាតិត្រកូលខ្ពស់ មានទ្រព្យសម្បត្តិច្រើន មានបុណ្យសក្តិធំ តែប្រព្រឹត្តអាក្រក់ដោយកាតវាចាចិត្ត អ្នកនោះចាត់ជាមនុស្សថោកទាប ផ្ទុយទៅវិញ អ្នកមានជាតិត្រកូលទាប ក្រទ្រព្យសម្បត្តិ គ្មានបុណ្យសក្តិ តែជាអ្នកប្រព្រឹត្តល្អដោយកាយវាចាចិត្ត អ្នកនោះចាត់ជាមនុស្សខ្ពង់ខ្ពស់ថ្លៃថ្លា តែព្រះអង្គយកអំពើរបស់មនុស្សជាខ្នាតសំរាប់វាស់ ។ ព្រះពុទ្ធបានចែកមនុស្សជាបួនប្រភេទ តាមអំពើដែលគេបានប្រព្រឹត្ត គឺបុគ្គលដែលទៅជាមនុស្សពេញលក្ខណ: គឺអ្នកមានធម៌ក្នុងខ្លួនដោយហោចណាស់ក៏មានសីល៥ដែលហៅថាមនុស្សោ, រូបរាងកាយជាមនុស្ស ប៉ុន្តែអំពើប្រព្រឹត្តវង្វេងមិនដឹងគុណមាតាបិតាជាដើម ហៅថាមនុស្សតិរច្ឆានោ ប្រែថាមនុស្សដូចជាសត្វ, រាងកាយជាមនុស្ស ប៉ុន្តែអំពើប្រព្រឹត្តលួចប្លន់ ឬមានទ្រព្យសម្បត្តិពុំធ្វើទានជាដើម ហៅថាមនុស្សបេតោ ប្រែថាមនុស្សដូចជាសត្វប្រេត, រូបរាងកាយជាមនុស្ស ប៉ុន្តែប្រព្រឹត្តបៀតបៀនកាប់សម្លាប់អ្នកដទៃជាដើម ហៅថាមនុស្សនេរយិកោ ប្រែថា មនុស្សដូចសត្វនរក ឬស្លាប់ទៅនឹងធ្លាក់សោយទុក្ខក្នុងនរក ។

ក្នុងន័យនេះ មនុស្សបើចង់បានភាពថ្លៃថ្នូរខ្ពង់ខ្ពស់ មានកេរ្តិ៍ឈ្មោះល្អ ត្រូវសាងខ្លួនឲ្យល្អ ត្រូវលះបង់អំពើអាក្រក់គ្រប់យ៉ាង ហើយជួយសង្គ្រោះអ្នកដទៃ ។ ពិសេសអ្នកដឹកនាំជាតិគ្រប់ជាន់ថ្នាក់ ត្រូវតែសាងល្អដោយត្រូវបំពេញកិច្ចការតាមមុខងារនិងនាទីរបស់ខ្លួន ជាទីពឹងរបស់ប្រជាពលរដ្ឋ ហើយទុកជាគំរូដ៏ល្អដល់អ្នកដឹកនាំក្រោយទៀត ។ កម្មនេះមានទំនាក់ទំនងទៅនឹងកាលទាំងបីគឺ អតីត: បច្ចុប្បន្ន និងអនាគត ។ បុគ្គលទោះបីមានកម្មពីអតីត: បានកសាងល្អយ៉ាងណាក៏ដោយ បើក្នុងបច្ចុប្បន្នប្រព្រឹត្តអាក្រក់, ផលនៃអំពើល្អពីមុនពុំអាចឲ្យផលបានឡើយ ដូច្នេះហើយបានជានៅក្នុងមង្គលសូត្រគម្ពីរពុទ្ធសាសនាពោលថា បើបានសាងល្អពីជាតិមុនហើយ ត្រូវដឹកលំខ្លួនឲ្យប្រពៃក្នុងបច្ចុប្បន្ននេះទៀត ទើបចាត់ជាមង្គលមានសេចក្តីចំរើន ។៚

❑